វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០៤ ខែ តុលា ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះ គឺ៖

- អត្រាពន្ធលើប្រាក់ចំណេញនៅប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីបីទាបជាងគេបំផុតនៅអាស៊ីអាគ្នេយ៍
- អតិផរណាចុះខ្សោយនៅក្នុងប្រទេសពីរដែលមានសេដ្ឋកិច្ចធំជាងគេនៅអាស៊ីអាគ្នេយ៍
- អង្គការពាណិជ្ជកម្មពិភពលោកកាត់បន្ថយទស្សនៈវិស័យលើផ្នែកពាណិជ្ជកម្មសកលលោកមកត្រឹម១,២% សម្រាប់ឆ្នាំ២០១៩

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### អត្រាពន្ធលើប្រាក់ចំណេញនៅប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់ទីបីទាបបំផុតនៅអាស៊ីអាគ្នេយ៍

អត្រាពន្ធលើប្រាក់ចំណេញនៅប្រទេសកម្ពុជាស្ថិតនៅក្នុងលំដាប់ថ្នាក់លេខរៀងទីបីទាបជាងគេបំផុតក្នុងតំបន់ ដែលមានអត្រា២០% បន្ទាប់ពីប្រទេសប្រ៊ុយណេ (១៨,៥%) និងសិង្ហបុរី (១៧%) យោងទៅតាមសេចក្តីរាយការណ៍របស់[កាសែតខ្មែរថាមស៍]() ដោយប្រើប្រាស់ទិន្នន័យដែលចងក្រងឡើងដោយ [Trading Economics]() ។

ដើម្បីទាក់ទាញការវិនិយោគ អត្រាពន្ធនៅប្រទេសកម្ពុជាប្រហាក់ប្រហែលនឹងប្រទេសថៃ និងវៀតណាម ដែលជាដៃគូប្រកួតប្រជែងនៅជិតកម្ពុជាបំផុត។ អត្រាពន្ធលើប្រាក់ចំណេញរបស់ប្រទេសហ្វីលីពីនខ្ពស់ជាងគេនៅក្នុងតំបន់គឺ ៣០% បន្ទាប់មកឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា ២៥% និងម៉ាឡេស៊ី ២៤%។

ទោះជាយ៉ាងណាក៏ដោយ និងគួរកត់សម្គាល់ថា អត្រាពន្ធទាំងនេះត្រូវបានបញ្ញត្តិដោយច្បាប់ មិនមែនជាអត្រាជាក់ស្តែងដែលសាជីវកម្មចំណាយពិតប្រាកដនោះទេ (អត្រាពន្ធបន្ទាប់ពីការធ្វើការរំសោធនកម្ម ដើម្បីលើកទឹកចិត្តដល់ការបង់ពន្ធ និងការវិនិយោគ)។

### តារាងប្រចាំសប្តាហ៍៖ ការចំណាយ ប្រាក់ឈ្នួលសេវាសាធារណៈ

យោងតាមលទ្ធផលនៃច្បាប់ទូទាត់ថវិកា កំណើនប្រាក់ឈ្នួលសេវាសាធារណៈសម្រាប់ផ្នែកស៊ីវិល និងផ្នែកការពារជាតិបាននឹងកំពុងកើនឡើងតាំងពីពេលកន្លងមករហូតដល់

បច្ចុប្បន្នក្នុងអត្រាជាមធ្យម ១៩%។ តារាងប្រចាំសប្តាហ៍នេះបានបង្ហាញ ថាអត្រាកំណើន មានការធ្លាក់ចុះពី២៤% ឆ្នាំ ២០១៧ មកត្រឹម១៤% ក្នុងឆ្នាំ ២០១៨។

ក្នុងនោះដែរ អត្រាកំណើនជាមធ្យម១៩%ត្រូវបានយកទៅប្រើដើម្បីជាការព្យាករណ៍លើគម្រោងចំណាយប្រាក់ឈ្នួលក្នុងរយៈពេល៦ឆ្នាំខាងមុខ ដែលការចំណាយនឹងត្រូវបានរំពឹងថា នឹងកើនឡើងទ្វេរដង ពី ៨ ៩៨៥ ប៊ីលានរៀលក្នុងឆ្នាំ ២០១៩ ដល់ ២១ ៣២៧ ប៊ីលានរៀលនៅឆ្នាំ២០២៤។

### ការព្យាករណ៍ប្រាក់ឈ្នួលសេវាសាធារណៈជាមួយអត្រាកំណើនជាមធ្យមថ្មីៗនេះ




ប្រភព៖ ច្បាប់ទូទាត់ថវិកាឆ្នាំ២០១៥-២០១៨ និងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៨ (ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

## ព័ត៌មាន និងទិន្ន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### នៅអាស៊ីអាគ្នេយ៍ អតិផរណាចុះខ្សោយនៅក្នុងប្រទេសពីរដែលមានសេដ្ឋកិច្ចធំជាងគេ

នៅក្នុងខែកញ្ញា អត្រាអតិផរណានៅក្នុងប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃមានការចុះខ្សោយ ដែលបានផ្តល់អំណាចរូបិយវត្ថុដល់ប្រទេសដែលមានទំហំសេដ្ឋកិច្ចធំជាងគេនៅអាស៊ីអាគ្នេយ៍ទាំងពីររក្សាអត្រាការប្រាក់អោយស្ថិតនៅក្នុងកម្រិតទាប ដើម្បីការពារសេដ្ឋកិច្ចរបស់ពួកគេពីការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច(Bloomberg)។

នៅក្នុងខែសីហាកំណើនតម្លៃទំនិញនៅឥណ្ឌូនេស៊ីបានធ្លាក់ចុះពី៣,៥% មកត្រឹម ៣,៤% ក្នុងខែកញ្ញា ទាបជាងការប៉ាន់ស្មានជាមធ្យម(មេដ្យាន)នៃការស្ទង់មតិរបស់សេដ្ឋវិទូរបស់សារព័ត៌មាន Bloomberg ដែលរំពឹងថានឹងមានកំណើន ៣,៥២% ។

អតិផរណារបស់ប្រទេសថៃបានធ្លាក់ចុះពី0,៥% ក្នុងខែសីហា មកត្រឹម 0,៣% ក្នុងខែកញ្ញា គឺទាបជាងការព្យាករណ៍ជាមធ្យម(មេដ្យាន) 0,៤១% ។

ថ្មីៗនេះ ធនាគារកណ្តាលរបស់ប្រទេសថៃ និងឥណ្ឌូនេស៊ីបានបន្ថយអត្រាការប្រាក់ខណៈដែលសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិនកំពុងតែមានភាពតានតឹង និងកំណើនសេដ្ឋកិច្ចពិភពលោកកំពុងតែធ្លាក់ចុះ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### អង្គការពាណិជ្ជកម្មពិភពលោកកាត់បន្ថយការព្យាការណ៍លើផ្នែកពាណិជ្ជកម្មសកលលោកមកត្រឹម១,២% សម្រាប់ឆ្នាំ ២០១៩

កាលពីថ្ងៃអង្គារ អង្គការពាណិជ្ជកម្មពិភពលោក (WTO) បានបន្ទាបការប៉ាន់ប្រមាណរបស់ពួកគេចំពោះកំណើនពាណិជ្ជកម្មពិភពលោកសម្រាប់ឆ្នាំ២០១៩ ចំនួន១,២% ដែលការរំពឹងទុកជាមុនមានចំនួន២,៦%។ ការប្រែប្រួលនេះបណ្តាលមកពីភាពតានតឹងផ្នែកពាណិជ្ជកម្ម និងការធ្លាក់ចុះទិន្នន័យក្នុងអំលុងពេលពាក់កណ្តាលឆ្នាំនេះ។

ពួកគេក៏បានកាត់បន្ថយការព្យាករណ៍សម្រាប់កំណើនពាណិជ្ជកម្មរបស់ពិភពលោកនៅឆ្នាំ២០២០ ពី៣% មកត្រឹម

២,៧% ដោយសារតែផលប៉ះពាល់ដែលបណ្តាលមកពីភាពមិនច្បាស់ផ្នែកពាណិជ្ជកម្មចំពោះការវិនិយោគ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ តុល្យភាពពាណិជ្ជកម្ម នៅបណ្តាប្រទេសអាស៊ាន និងអតិផរណានៅសហរដ្ឋអាមេរិច។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃច័ន្ទ ទី០៧ ខែតុលា ឆ្នាំ២០១៩

- អត្រារូបិយប័ណ្ណបរទេសនៃទុនបម្រុងរបស់ជប៉ុន សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្មរបស់ប៊្រុយណេ សម្រាប់ខែកក្កដា
- តុល្យភាពពាណិជ្ជកម្មរបស់តៃវ៉ាន់ សម្រាប់ខែកញ្ញា

ថ្ងៃអង្គារ ទី ០៨ ខែតុលា ឆ្នាំ២០១៩

- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែសីហា
- ការចំនាយលក្ខណៈគ្រួសាររបស់ជប៉ុន សម្រាប់ខែសីហា
- គណនីចរន្តរបស់ជប៉ុន សម្រាប់ខែសីហា
- សន្ទស្សន៍ថ្លៃនៃការផលិតរបស់អាមេរិច សម្រាប់ខែកញ្ញា

ថ្ងៃពុធ ទី ០៩ ខែតុលា ឆ្នាំ២០១៩

- សន្ទស្សន៍តម្លៃលក់រាយរបស់ហ្វីលីពីន សម្រាប់ខែសីហា
- ការបញ្ជាទិញឧបករណ៍ម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែកញ្ញា
- ការលក់រាយរបស់ឥណ្ឌូនេស៊ី សម្រាប់ខែសីហា

ថ្ងៃព្រហស្បតិ៍ ទី១០ ខែតុលា ឆ្នាំ២០១៩

- ការរំពឹងទុកនូវអត្រាអតិផរណារបស់អូស្ត្រាលី សម្រាប់ខែតុលា
- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន សម្រាប់ខែសីហា
- ទំនុកចិត្តអតិថិជនរបស់ថៃ សម្រាប់ខែកញ្ញា
- ការបញ្ជាទិញម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែតុលា
- តុល្យភាពពាណិជ្ជកម្មរបស់អង់គ្លេស សម្រាប់ខែសីហា
- ផ.ស.ស. របស់អង់គ្លេស សម្រាប់ខែសីហា
- អតិផរណារបស់អាមេរិច សម្រាប់ខែកញ្ញា

ថ្ងៃសុក្រ ទី ១១ ខែតុលា ឆ្នាំ២០១៩

- កំណើន ផ.ស.ស. របស់សិង្ហបុរី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩
- ការលក់រាយរបស់សិង្ហបុរី សម្រាប់ខែសីហា
- អត្រានិកម្មភាពរបស់ម៉ាឡេស៊ី សម្រាប់ខែសីហា
- ការពិភាក្សាពាណិជ្ជកម្ម រវាងអាមេរិច និងចិន